# កញ្ចប់ឧបករណ៍អប់រំដើម្បី ផ្លាស់ប្តូរទង្វើអំពីការធ្វើការនៅ ក្រៅប្រទេសដោយស្របច្បាប់

កម្មវិធីបញ្ឈប់ការជួញដូរមនុស្សអង្គការទស្សនៈពិភពលោក

រៀបចំដោយ៖ 17 TRIGGERS

## ៤. អត្ថបទកិច្ចសន្ទនាតាមទូរស័ព្ទរបស់មជ្ឈមណ្ឌលពលករទេសន្តរប្រវេសន៍ (MRC)

ប្រធានបទ៖ ហេតុអ្វីត្រូវប្រើភ្នាក់ងារស្របច្បាប់?
ក្រុមគោលដៅ៖ យុវជនអាយុ១៧-២៤
មធ្យោបាយ៖ បុគ្គលិក MRC
ភាសា៖ ខ្មែរ
ទម្រង់៖ អត្ថបទសន្ទនាតាមទូរស័ព្ទរយៈពេល១-២នាទី

### ទិដ្ឋភាពរួមនៃឧបករណ៍

យោងតាមកិច្ចប្រជុំជាមួយអង្គការទស្សនៈពិភពលោក យើងបានឯកភាពគ្នាថា MRC គឺជាកន្លែងល្អបំផុតសម្រាប់យុវជនស្វែងរកព័ត៌មាន ប្រសិនបើពួកគេមានសំណួរពីការធ្វើចំណាកស្រុក។ ក៏ប៉ុន្តែ ប្រសិនបើបុគ្គលិកមជ្ឈមណ្ឌលមិនបានត្រៀមខ្លួនក្នុងការឆ្លើយឲ្យបានត្រឹមត្រូវចំពោះសំណួររបស់យុវជន ឬផ្តល់សេវាកម្មមិនល្អ យុវជនអាចមិនស្តាប់ការណែនាំរបស់មជ្ឈមណ្ឌល ហើយថែមទាំងប្រាប់មិត្តភក្តិគេមិនឲ្យទាក់ទងមកផងដែរ។ ខ្លឹមសារសន្ទនាតាមទូរស័ព្ទបង្កើតឡើងក្នុងគោលបំណងដើម្បីណែនាំបុគ្គលិកមជ្ឈមណ្ឌលពីសំណួរមួយចំនួនក្នុងការឆ្លើយទូរស័ព្ទ នៅពេលយុវជនទូរស័ព្ទមក និងធានាថាពួកគេផ្តល់យោបល់បានត្រឹមត្រូវ និងទទួលបានបទពិសោធន៍វិជ្ជមាន។

### របៀបប្រើឧបករណ៍

ខ្លឹមសារសន្ទនាតាមទូរស័ព្ទនេះ នឹងត្រូវបានប្រើប្រាស់ដោយបុគ្គលិកមជ្ឈមណ្ឌល ជាមួយក្រុមគោលដៅ នៅពេលណាពួកគេទូរស័ព្ទមកសុំព័ត៌មានបន្ថែម។ ខាងក្រោមនេះ គឺជាជំហានក្នុងការប្រើប្រាស់ខ្លឹមសារសន្ទនាឲ្យមានប្រសិទ្ធភាព៖

### ជំហាន

1. បុគ្គលិក MRC ហាត់អានខ្លឹមសារឲ្យលឺៗទៅកាន់ខ្លួនឯង ដើម្បីដឹងថាខ្លឹមសារនោះគឺនិយាយអំពីអ្វី។ ធ្វើបែបនេះយ៉ាងតិច១០ដង។

2. ហាត់ ឬសំដែងសាកល្បងធ្វើបែបនេះជាមួយអ្នករួមការងារ ដើម្បីដឹងថាខ្លួនឯងមានទំនុកចិត្ត និងមានភាពងាយស្រួលក្នុងការប្រើប្រាស់ខ្លឹមសារនេះឬអត់។ ធ្វើបែបនេះយ៉ាងតិច៣ដង។

3. នៅពេលដឹងថាខ្លួនឯងមានទំនុកចិត្តក្នុងការប្រើអត្ថបទនេះហើយ អ្នកអាចត្រៀមខ្លួនជាស្រេចក្នុងការប្រើប្រាស់ខ្លឹមសារនេះជាមួយអ្នកទូរស័ព្ទចូលបាន។

(សូមមើលខ្លឹមសាររបស់អត្ថបទ នៅទំព័រខាងក្រោម)

## ខ្លឹមសារអត្ថបទសម្រាប់ការឆ្លើយទូរស័ព្ទរបស់បុគ្គលិក MRC

### អត្ថបទគម្រូសម្រាប់ការស្វាគមន៍

បុគ្គលិក MRC ៖ មជ្ឈមណ្ឌលពលករទេសន្តរប្រវេសន៍ សូមជម្រាបសួរ។
សូមអរគុណដែលទូរស័ព្ទមក ដើម្បីទទួលបានសេវាកម្មរបស់យើងខ្ញុំ។ ខ្ញុំបាទ/នាងខ្ញុំឈ្មោះ ...................... តើបង/ប្អូនមានអ្វីឲ្យខ្ញុំជួយដែរ?

### គម្រូកិច្ចសន្ទនារវាងអតិថិជន និងបុគ្គលិកMRC

អតិថិជន៖ ខ្ញុំកំពុងគិតចង់ទៅធ្វើការក្រៅប្រទេស ប៉ុន្តែអត់ដឹងថាត្រូវធ្វើម៉េចផង។ តើបងឯងជួយខ្ញុំបានអត់?

បុគ្គលិក MRC ៖ វិធីធ្វើចំណាកស្រុកទៅធ្វើការក្រៅប្រទេសដោយសុវត្ថិភាពបំផុតនោះ គឺត្រូវប្រើ ភ្នាក់ងារស្របច្បាប់។ វាអាចការពារប្អូនពីគ្រោះថ្នាក់ផ្សេងៗដូចជា៖ ការកេងប្រវ័ញ្ច ការរំលោភបំពាន ការជួញដូរ ឬធ្វើការដោយគេមិនបើកប្រាក់ខែឲ្យ។ ភ្នាក់ងារស្របច្បាប់នឹងជួយប្អូនរៀបចំឯកសារចាំបាច់ផ្សេងៗ ដែលជួយសម្រួលក្នុងការធ្វើដំណើរទៅ និងមកពីប្រទេសក្រៅ ដោយស្របច្បាប់ សុវត្ថិភាព និងងាយស្រួល។

បុគ្គលិក MRC ៖ តើប្អូនមានលិខិតឆ្លងដែនដែរឬទេ?
បុគ្គលិក MRC ៖

- ប្រសិនបើអត់មានទេ រឿងទី១ដែលភ្នាក់ងារស្របច្បាប់នឹងជួយប្អូននោះ គឺធ្វើលិខិតឆ្លងដែនឲ្យប្អូន។
- ប្រសិនបើប្អូនមានលិខិតឆ្លងដែន វាជាការល្អណាស់។ បន្ទាប់មក ភ្នាក់ងារនោះនឹងជួយប្អូនឲ្យទទួលបានកិច្ចសន្យាការងារ ទិដ្ឋាការ និងលិខិតអនុញ្ញាតការងារ។ ឯកសារទាំងអស់នេះគឺត្រូវការជាចាំបាច់ក្នុងការទៅធ្វើការនៅក្រៅប្រទេសដោយស្របច្បាប់។ ការរត់ការនឹងចំណាយពេលប្រហែល ១២ អាទិត្យ អាស្រ័យលើថា តើប្អូនមានឯកសារអ្វីខ្លះ ហើយពួភ្នាក់ងារស្របច្បាប់ក៏អាចពន្យល់ប្អូននូវព័ត៌មានលម្អិតផ្សេងៗទៀតផងដែរ។
- ជាពិសេសជាងនេះទៅទៀត បើសិនជាប្អូនចំណាកស្រុកតាមមេខ្យល់ ប្អូននឹងប្រឈមនឹងគ្រោះភ័យ។ ភ្នាក់ងារស្របច្បាប់ វាចំណាយពេលយូរមែន ប៉ុន្តែប្អូននឹងត្រូវបានធានាថានឹងមានសុវត្ថភាពជានិច្ច។

បុគ្គលិក MRC ៖ អាស័យដ្ឋានរបស់ប្អូននៅទីណាដែរ បងនឹងងាយស្រួលប្រាប់ ថាភ្នាក់ងារស្របច្បាប់ណាដែលនៅជិតកន្លែងរបស់ប្អូន។
អតិថិជន៖ ចាំឬបាទ បង!
កំណត់សម្គាល់សម្រាប់បុគ្គលិក MRC៖ ឲ្យព័ត៌មានលម្អិតអំពីភ្នាក់ងារស្របច្បាប់ដែលនៅជិតផ្ទះរបស់អតិថិជន។

បុគ្គលិក MRC ៖ ប្អូនមានសំនួរអីបន្ថែមទៀតទេ?
អតិថិជន៖ ទេ សូមអរគុណ។

បុគ្គលិក MRC ៖ មិនអីទេ។ សូមជំរាបលា។

សំនួរ និងចម្លើយដែលអតិថិជនតែងតែសួរ៖

អតិថិជន៖ ដើម្បីរត់ការទៅធ្វើការនៅក្រៅប្រទេស អស់លុយប៉ុន្មានដែរ?

បុគ្គលិក MRC៖ តម្លៃ គឺអាស្រ័យលើភ្នាក់ងារស្របច្បាប់នីមួយៗ ប៉ុន្តែតម្លៃហ្នឹងអាចពី ១៨០ដុល្លារ ទៅ ៣០០ដុល្លារ អាស្រ័យលើឯកសារដែលប្អូនត្រូវការ។ តម្លៃហ្នឹងរួមមានដូចខាងក្រោម៖

- លិខិតឆ្លងដែន៖ តម្លៃចាប់ពី ១១៥ ទៅ ១២០ ដុល្លា
- ទិដ្ឋាការ៖ តម្លៃចាប់ពី ២០ ទៅ ២៥ ដុល្លា
- លិខិតអនុញ្ញាតការងារ៖ តម្លៃចាប់ពី ១០ ទៅ ១២ ដុល្លា
- កិច្ចសន្យាការងារ៖ តម្លៃចាប់ពី ៦០ ទៅ ៩២ ដុល្លា
- កម្រៃជើងសារ/ថ្លៃសេវាកម្មរបស់ភ្នាក់ងារ៖ តម្លៃចាប់ពី ៦០០ ទៅ ៧០០ ដុល្លា

សារសំខាន់នៃការមានឯកសារស្របច្បាប់គ្រប់គ្រាន់ និងត្រឹមត្រូវ វានឹងអាចជួយប្អូនច្រើនណាស់ ហើយថែមទាំងធានាពីការរកប្រាក់ចំណូលរបស់ប្អូន ក៏ដូចជាសុវត្ថិភាពរបស់ប្អូនផងដែរ។ ឧទាហរណ៍៖ ប្រសិនបើប្អូនទៅធ្វើការក្រៅប្រទេសជាមួយមេខ្យល់ ដែលយកលុយពីប្អូនត្រឹមតែ២០០ដុល្លារ ប្អូនប្រហែលជាអាចឆ្លងទៅប្រទេសមួយទៀតដោយឆាប់រហ័ស ប៉ុន្តែនេះគឺជាសកម្មភាពខុសច្បាប់ ដែលមានន័យថាប្អូននឹងគ្មានសិទ្ធិអ្វីទាំងអស់។ មេខ្យល់ប្រហែលជាសន្យាថានឹងឲ្យការងារល្អទៅប្អូន ប៉ុន្តែការពិតប្អូនប្រហែលជាត្រូវគេបង្ខំឲ្យធ្វើការពិបាកហួសកម្លាំង រងការរំលោភបំពានទាំងផ្លូវកាយ និងផ្លូវចិត្ត ហើយប្អូនក៏ប្រហែលជាមិនទទួលបានប្រាក់ខែថែមទៀតផង។ ដូច្នេះប្អូនគួរតែជឿខ្ញុំទៅ។ សុខចិត្តចាំបន្តិចចុះ ដើម្បីឲ្យបានធ្វើដំណើរ និងធ្វើការដោយស្របច្បាប់ ប្រកបដោយសុវត្ថិភាព។ ដូចពាក្យចាស់ថា "សន្សឹមកុំបំបោល ក្រែងមិនដល់ដូចប្រាថ្នា" ណាប្អូន! បងសង្ឃឹមថាព័ត៌មានទាំងនេះនឹងជួយប្អូនឲ្យសម្រេចចិត្តបានត្រឹមត្រូវ។ តើប្អូនចង់ដឹងពីអ្វីផ្សេងទៀតទេ?

សំណួរ៖ តើទម្រាំបានឯកសារចាំបាច់ទាំងអស់ វាត្រូវចំណាយពេលប៉ុន្មាន?

ចម្លើយ៖ ជាធម្មតា រាល់ឯកសារទាំងអស់រួមទាំងលិខិតឆ្លងដែន និងទិដ្ឋាការ អាចត្រូវការពេលវេលាប្រហែល ២ទៅ៣ខែ។ ដើម្បីជួយសម្រួលឲ្យដំណើរការបានលឿនបន្តិច ប្អូនគួរតែយកឯកសារសំខាន់ៗទៅជាមួយនៅពេលដែលប្អូនទៅជួបជាមួយភ្នាក់ងារស្របច្បាប់។ ឯកសារសំខាន់ៗទាំងនោះមាន សៀវភៅគ្រួសារ រូបថត ៤X៦ ឬអត្តសញ្ញាណបណ្ណដើម្បីធ្វើលិខិតឆ្លងដែន។ ប្រសិនបើប្អូនមានលិខិតឆ្លងដែនរួចហើយ ប្អូនកុំភ្លេចយកទៅជាមួយពេលទៅការិយាល័យភ្នាក់ងារស្របច្បាប់ ដែលនេះអាចជួយឲ្យដំណើរការ ទៅធ្វើការក្រៅប្រទេសរបស់ប្អូនបានលឿន។

សំណួរ៖ តើខ្ញុំអាចទាក់ទងមកគ្រួសាររបស់ខ្ញុំបានយ៉ាងដូចម្តេចនៅពេលដែលខ្ញុំទៅដល់ប្រទេសគោលដៅ?

ចម្លើយ៖

- ត្រូវយកទូរស័ព្ទតាមខ្លួនជានិច្ច ធ្វើដូច្នេះប្អូនអាចទាក់ទងមកគ្រួសារប្អូននៅពេលដែលប្អូននៅឆ្ងាយបាន។ ប្អូនគួរតែទិញស៊ីមកាតថ្មីសម្រាប់ទូរស័ព្ទប្អូនពេលទៅដល់ប្រទេសគោលដៅ។ ប្រសិនបើប្អូនមិនមានទូរស័ព្ទទេ ប្រទេសគោលដៅមួយចំនួនដូចជា ប្រទេសថៃ ឬម៉ាឡេស៊ី មានហាងអ៊ីនធឺណែតច្រើនដែលប្អូនអាចបង់លុយដើម្បីទូរស័ព្ទមកគ្រួសារប្អូនបាន។
- ត្រូវចងចាំ ឬកត់ទុក លេខទូរស័ព្ទរបស់គ្រួសាររបស់ប្អូន។
- ត្រូវចងចាំលេខទូរស័ព្ទ ឬកត់ទុកលេខទូរស័ព្ទរបស់អ្នកផ្សេងដែលមានការងារដូចប្អូន។
- ត្រូវចងចាំលេខទូរស័ព្ទ ឬកត់ទុកលេខទូរសព្ទ័របស់មនុស្សដែលប្អូនស្គាល់ដែលរស់នៅក្នុងប្រទេសគោលដៅ ដូចជាមិត្តភក្រ ឬសាច់ញាតិ។
- ត្រូវចងចាំ ឬកត់ទុកលេខទូរស័ព្ទរបស់ស្ថានទូតរបស់ប្អូនដែលនៅក្រៅប្រទេស។
- ត្រូវចងចាំ ឬកត់ទុកលេខទូរស័ព្ទដែលត្រូវទាក់ទងក្នុងករណីមានគេចាប់រំលោភបំពាន។
- ចុចលេខ៖ ០០១ + លេខប្រទេស(៨៥៥) + លេខទូរស័ព្ទ (ដោយគ្មានលេខ០)

ឧទាហរណ៍៖ ប្រសិនបើលេខទូរស័ព្ទនៅក្នុងប្រទេសកម្ពុជា ០១២ ៤៤៤ ៥៤៤ នោះប្អូនអាចទូរស័ព្ទពីប្រទេសថៃដោយចុចលេខ៖ ០០១៨៥៥១២៤៤៤៥៤៤

សំណួរ៖ តើខ្ញុំអាចទៅធ្វើការនៅប្រទេសថៃដោយគ្មានលិខិតឆ្លងដែនបានទេ?

ចម្លើយ៖ ទេទេ វាមិនស្របច្បាប់ទេ។ ប្រសិនបើប្អូនធ្វើបែបនេះ ប្អូននឹងប្រឈមនឹងគ្រោះថ្នាក់ក្នុងការកេងប្រវ័ញ្ច ការចាប់ខ្លួន ការរំលោភបំពាន គ្មានប្រាក់ខែ។ ប្អូននឹងគ្មានសិទ្ធស្របច្បាប់ទេ។

លិខិតឆ្លងដែន គឺជាឯកសារដ៏សំខាន់១សម្រាប់បញ្ជាក់អត្តសញ្ញាណបុគ្គលម្នាក់។ ម្យ៉ាងទៀត លិខិតឆ្លងដែនពិតជាចាំបាច់ខ្លាំងណាស់នៅពេលដែលប្អូនមានគម្រោងចង់ធ្វើដំណើរទៅកាន់ប្រទេសផ្សេងៗដើម្បីធ្វើការ ពីព្រោះថាលិខិតឆ្លងដែនផ្ទុកព័ត៌មានដែលអាចបញ្ជាក់ថាប្អូនជាអ្នកណា ហើយមកពីណា។«